edu



# កំពូលអ្នកមាន នៅទីក្រុង បាប៊ីឡូន





ប្រែសម្រួល : ដោ នីដា

**កំពូលអ្នកមាន**នៅក្រុងបាប៊ីឡូន

ISBN-13:978-9924-9076-0-2

ប្រែសម្រួលដោយ ដោ នីដា

រក្សាសិទ្ធគ្រប់យ៉ាងដោយ **edu Books**

បោះពុម្ពលើកទី២

eduperbox@gmail.com

facebook.com/edubooks

# មាតិកា


១. កិត្យានុភាពរបស់ក្រុង បាប៊ីឡូន ( Babylon ) ............................ ០១

២. បុរសដែលចង់បានមាស ........................................................០៦

៣. កំពូលអ្នកមាននៅក្រុង បាប៊ីឡូន ..............................................១៤

៤. រូបមន្ត ៧ យ៉ាង សម្រាប់ព្យាបាលកាបូបដែលគ្មានលុយ .............. ២៨

ក. ចាប់ផ្តើមធ្វើឲ្យកាបូបទ្បើងប៉ោង ...............................................៣២

ខ. ទប់ស្កាត់ការចំណាយ ........................................................ ៣៥

គ. ធ្វើឲ្យចំនួនមាសកើនទ្វេដង ................................................ ៣៨

ឃ. ការពារទ្រព្យដែលរកបានកុំឲ្យបាត់បង់ ....................................៤១

ង. សង់ផ្ទះផ្ទាល់ខ្លួនមួយដើម្បីបង្កើនប្រាក់ចំណេញ .................... ៤៣

ច. រៀបចំប្រាក់ចំណូលសម្រាប់ថ្ងៃអនាគត.....................................៤៤

ឆ. បង្កើនសមត្ថភាពរកចំណូល................................................. ៤៧

៥. ទេព្តាសំណាង .......................................................................៥១

៦. ក្បួនរកមាសប្រាំយ៉ាង........................................................... ៦៧

៧. អ្នកចងការមាសនៅ បាប៊ីឡូន ............................................... ៨៣

៨. ជញ្ជាំងក្រុង បាប៊ីឡូន .............................................................៩៩

៩. ឈ្មួញសត្វអូដ្ឋនៅ បាប៊ីឡូន.............................................. ១០៤

១០. បុរសដែលសំណាងបំផុតនៅ បាប៊ីឡូន................................១២៥

# កិត្យានុភាពរបស់ក្រុង បាប៊ីឡូន

« **បើ**អ្នកដឹងរូបមន្តដើម្បីរកលុយ
អ្នកអាចរកលុយបានច្រើនតាមសេចក្ដីប្រាថ្នា »

**នៅ**ក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ បាប៊ីឡូន គឺជាទីក្រុងដ៏ថ្កុំថ្កើនបំផុត គ្មានទីក្រុងណាអាចប្រៀបបានឡើយ។ ឈ្មោះ បាប៊ីឡូន គឺជានិមិត្តរូបនៃរតនសម្បត្តិ និងភាពរុងរឿង។ រតនសម្បត្តិដូចជា ត្បូង មាសប្រាក់ កែវកង មានច្រើនរាប់មិនអស់។ បើគិតមួយភ្លែតគេមុខជាយល់ថា បាប៊ីឡូន ប្រាកដជាស្ថិតនៅចំទីតាំងល្អបំផុតណាមួយនៃតំបន់ត្រូពិចដែលសម្បូរទៅដោយព្រៃឈើ និង រ៉ែ ជាក់ជាមិនខាន។ តែជាតុពិតបាប៊ីឡូនគឺឋិតនៅតាមដងទន្លេ អឺប្រ្ហាត( Euphrates ) ដែលជាតំបន់វាលរាប និង ជ្រលងភ្នំគ្មានជីជាតិ។ គ្មានព្រៃឈើ គ្មានរ៉ែ សូម្បីតែថ្មសម្រាប់ធ្វើសំណង់ក៏គ្មាន។ ម៉្យាងវិញទៀត បាប៊ីឡូនក៏មិនឋិតនៅចំផ្លូវពាណិជ្ជកម្មថែមទៀតផង។ ចំណែកឯភ្លៀងក៏មិនមានគ្រប់គ្រាន់សម្រាប់ដាំដំណាំដែរ។ តាមពិតកិត្យានុភាពរបស់បាប៊ីឡូនគឺកើតចេញពីសមត្ថភាព និង ទេពកោសល្យរបស់មនុស្សសុទ្ធសាធ គឺសមត្ថភាពកែច្នៃជោគវាសនារបស់ខ្លួនរហូតទទួលជោគជ័យដូចអ្វីដែលចង់បានដោយប្រើគ្រប់មធ្យោបាយដែលមាន។ កម្លាំងមនុស្សបានកសាងក្រុងបាប៊ីឡូនឲ្យក្លាយជាមជ្ឈមណ្ឌលកសិកម្ម ជាទីក្រុងជំនួញដ៏ធំសម្បើម និង ជាទីក្រុងកុះករដោយពួកអភិជនរស់នៅ បានរយៈពេលរហូតដល់រាប់ពាន់ឆ្នាំ។ នៅពេលកម្លាំងមនុស្សត្រូវបាត់បង់ បាប៊ីឡូនក៏ក្លាយជាក្រុងទទេស្អាត គ្របដណ្ដប់ទៅដោយវាលខ្សាច់រហូតមកទល់សព្វថ្ងៃនេះ។

ធម្មជាតិបានផ្ដល់ឲ្យបាប៊ីឡូននូវវត្ថុពីរយ៉ាងតែប៉ុណ្ណោះគឺ **ដី** និង **ទឹកទន្លេ** ប៉ុន្តែបាប៊ីឡូនមានវិស្វករដែលមានសមត្ថភាពខ្ពស់ អាចបង្វែរទឹកទន្លេ

អឺប្រាត ដោយប្រើទំនប់និងប្រឡាយទឹក បង្កើតបានជាប្រព័ន្ធធារាសាស្ត្រដ៏ធំសម្បើម និង ដ៏ជោគជ័យបំផុតនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ។ ទឹកហូរចេញពីជ្រលងភ្នំបានចាក់ចូលទៅតាមប្រឡាយទឹកនានាដែលត្រូវគេប្រើប្រាស់ដើម្បីស្រោចស្រពដំណាំ។ ប្រព័ន្ធនេះកើតចេញពីភាពប៉ិនប្រសប់ដ៏ឈ្លាសវៃបំផុតរបស់មនុស្សកាលសម័យនោះ។ ភោគផលកសិកម្មដ៏ច្រើនអស្ចារ្យបានកើតចេញពីប្រព័ន្ធធារាសាស្ត្រទាំងអស់នោះ ហើយច្រើនរហូតដល់ពិភពលោកមិនធ្លាប់បានឃើញពីមុនមក។

អ្នកវិទ្យាសាស្ត្រជាច្រើនយល់ថាបាប៊ីឡូន និង ទីក្រុងនានានៅតាមបណ្តោយទន្លេ អឺប្រាត នេះ មានអាយុកាលចាស់ជាងទីក្រុងបុរាណផ្សេងៗទៀតដែលមាននៅក្នុងកំណត់ត្រា។ អាយុកាលពិតប្រាកដគឺ ៨,000ឆ្នាំ មុនមកម្លេះ។ មនុស្សដែលបានចូលមករស់នៅក្នុងក្រុងបាប៊ីឡូន គឺជនជាតិស៊ូមើ ហើយពួកគេរស់ក្នុងទីក្រុងដែលមានជញ្ជាំងព័ទ្ធជុំវិញ។ ពួកគេគឺជាមនុស្សមានការអប់រំខ្ពស់និងមានចំណេះដឹងជ្រៅជ្រះ។ ដោយយោងទៅលើប្រវត្តិសាស្ត្រ ពួកគេគឺជាមនុស្សដំបូងបង្អស់ដែលជា វិស្វករ ជាតារាវិទូ គណិតវិទូ ហើយក៏ជាអ្នកបង្កើតអក្សរសម្រាប់ប្រើប្រាស់មុនគេដែរ។ ប្រជាជនបាប៊ីឡូនជាអ្នកជំនាញខាងហិរញ្ញវត្ថុ និង ពូកែធ្វើពាណិជ្ជកម្ម។ ពួកគេគឺអ្នកបង្កើតឲ្យមានប្រាក់មុនគេដើម្បីធ្វើការដោះដូរផលិតផល និងជាអ្នកបង្កើតកិច្ចសន្យា និង ឯកសារសម្គាល់សិទ្ធលើទ្រព្យសម្បត្តិថែមទៀតផង។

ក្រៅពីប្រព័ន្ធធារាសាស្ត្រ វិស្វករបាប៊ីឡូនបានធ្វើគម្រោងធំអស្ចារ្យមួយទៀត គឺបានរៀបចំឲ្យមានប្រព័ន្ធលូបង្ហូរទឹកដើម្បីប្រែក្លាយតំបន់វាលភក់ដ៏ធំសម្បើមមួយនៅមាត់ទន្លេ អឺប្រាត និង ទីហ្គ្រីស ឲ្យទៅជាតំបន់កសិកម្ម។

លក្ខណៈពិសេសមួយទៀតរបស់បាប៊ីឡូន គឺជញ្ជាំងដែលព័ទ្ធជុំវិញទីក្រុង។ វាគឺជាជញ្ជាំងដ៏មហិមា រហូតដល់បុរាណវិទូបានដាក់ចំណាត់ថ្នាក់ជញ្ជាំងនោះថាជា «រតនសម្បត្តិមួយក្នុងចំណោមរតនសម្បត្តិទាំងប្រាំពីរនៅលើ

លោក » ដូចទៅនឹងប្រាសាទ**ពីរ៉ាមីត**នៅប្រទេស អេហ្ស៊ីប(Egypt) ដែរ ។ ម្ចាស់ក្សត្រី សិមើរ៉ាម៉ីស(Semiramis) ត្រូវបានគេចាត់ទុកថាជាអ្នកផ្ដើមគំនិតក្នុងការកសាងជញ្ជាំងទីក្រុងឡើង ប៉ុន្តែគេនៅមិនទាន់រកឃើញស្នាមជញ្ជាំងដែលទ្រង់បានកសាងមុនដំបូងគេបង្អស់នៅឡើយទេ ដូច្នេះកម្ពស់របស់វាក៏នៅមិនទាន់មាននរណាដឹងឲ្យប្រាកដដែរ។ តែបើតាមអ្នកនិពន្ធមុនៗ ដែលសរសេរអំពីប្រវត្តិនៃទីក្រុងនេះ បានធ្វើការប៉ាន់ប្រមាណថាវាអាចមានកម្ពស់ប្រហែល ១៥m ទៅ ១៨m និងធ្វើអំពីដុំឥដ្ឋដោយមានគូរទឹកព័ទ្ធជុំវិញ។

ជញ្ជាំង ដែលសាងសង់ក្រោយៗមកទៀត កាន់តែធំសម្បើមឡើងៗ និងត្រូវបានចាប់ផ្ដើមកសាងប្រហែលជា ៦00ឆ្នាំ មុន គ.ស ដោយស្ដេចព្រះនាម ណាបូប៉ូឡាសា(Nabopolassar)។ ដោយសារគម្រោងសាងសង់នោះធំមហិមាពេក ព្រះអង្គទ្រង់ចូលទីវង្គត់មុនសំណង់ជញ្ជាំងត្រូវបានបញ្ចប់ ដូច្នេះគម្រោងត្រូវបន្តទៅព្រះរាជបុត្ររបស់ទ្រង់ព្រះនាម នេប៊ូឆានេហ្សា(Nebuchadnezzar) ។

កម្ពស់និងប្រវែងរបស់ជញ្ជាំងក្រោយនេះធំអស្ចារ្យ ដែលធ្វើឲ្យយើងនឹកស្មានមិនដល់។ វាត្រូវបានគេជឿថាមានកម្ពស់រហូតដល់ ៥0m គឺស្មើអាគារកម្ពស់ ១៥ជាន់ និងប្រវែងសរុបប្រហែលជាចន្លោះពី ១៤ ទៅ ១៧ គីឡូម៉ែត្រឯណោះ។ ចំណែកទំហំខាងលើជញ្ជាំងធំរហូតដល់រទេះសេះចំនួនប្រាំមួយអាចបរប្រណាំងគ្នាបាន ប៉ុន្តែបច្ចុប្បន្នជញ្ជាំងនេះបាក់បែកនៅសល់តែគ្រឹះនិងគូទឹកព័ទ្ធជុំវិញតែប៉ុណ្ណោះ។ ក្រៅពីរងការខូចខាតដោយកន្លែងៗ ជនជាតិអារ៉ាប់មួយចំនួនបានធ្វើឲ្យជញ្ជាំងនេះខូចខាតទាំងស្រុងតែម្ដង ដោយជីកកកាយយកដុំឥដ្ឋទៅសង់លំនៅដ្ឋានរបស់ខ្លួន។

ជញ្ជាំងក្រុងបាប៊ីឡូនបានធ្វើឲ្យសត្រូវដែលមកឈ្លានពានបរាជ័យ។ ស្ដេចជាច្រើនព្យាយាមដណ្ដើមកាន់កាប់ទីក្រុងមួយនេះ ប៉ុន្តែមិនសម្រេច។ ចំនួនកងទ័ពបញ្ជូនមកក្នុងសង្គ្រាមដើម្បីវាយកាន់កាប់ក្រុងបាប៊ីឡូននៅកាលពីសម័យនោះ គឺមិនតូចតាចនោះទេ។ អ្នកប្រវត្តិសាស្ត្របាននិយាយថា វាមានទ័ពសេះ

រហូតដល់ ១០,០០០ ទ័ពរទេះសេះចំនួន ២៥,០០០ ទ័ពថ្មើរជើងចំនួន ១,២០០ កង ហើយក្នុងមួយកងៗមានទាហានដល់ទៅ ១,០០០នាក់ ។ ជាធម្មតា គេត្រូវការពេលពីរទៅបីឆ្នាំដើម្បីរៀបចំស្បៀងនិងអាវុធដើម្បីត្រៀមធ្វើសង្គ្រាមនេះបាន។

មកទល់ឆ្នាំ ៥៤០ មុន គ.ស បាប៊ីឡូនមិនទាន់ធ្លាប់ធ្លាក់ក្រោមការគ្រប់គ្រងរបស់សត្រូវមួយណានៅឡើយទេ ហើយសូម្បីតែជញ្ជាំងក្រុងក៏មិនទាន់មាននរណាអាចវាយរំលំបាននៅឡើយដែរ។ ការធ្លាក់ចុះនៃក្រុងបាប៊ីឡូនមានលក្ខណៈខុសពីធម្មតា សឹងតែមិនគួរឲ្យជឿ។ សាយរ៉ឹស (Cyrus) ដែលជាក្រុមវាតទីនិយមមួយកាលសម័យនោះ ចង់វាយទំលុះជញ្ជាំងដ៏រឹងមាំនេះ។ ពេលនោះទីប្រឹក្សារបស់ស្តេចបាប៊ីឡូនព្រះបាទ ណាប៊ូនីដាស់ បានទូលថ្វាយព្រះអង្គឲ្យចេញទ័ពប្រយុទ្ធតទល់នឹង សាយរ៉ឹស តែម្តង គឺបំណងដើម្បីកុំឲ្យសត្រូវមកដល់ជើងក្រុងទាន់។ ក្រោយពីកងទ័ពបាប៊ីឡូនបរាជ័យម្តងហើយម្តងទៀត កងទ័ពដែលនៅសេសសល់បានភៀសខ្លួនចេញពីទីក្រុងអស់ ធ្វើឲ្យ សាយរ៉ឹស អាចចូលកាន់កាប់និងប្រមូលយកទ្រព្យសម្បត្តិទាំងអស់ដោយគ្មានអ្នកណាហ៊ានតតាំង។

ក្រោយពីនោះមក អំណាច និង កិត្យានុភាពរបស់បាប៊ីឡូន បានធ្លាក់ចុះបន្តិចម្តងៗអស់រយៈពេលពីរទៅបីរយឆ្នាំបន្តបន្ទាប់គ្នា រហូតដល់ត្រូវបានគេបោះបង់ចោលទាំងស្រុង ហើយក្លាយទៅជាទីក្រុងវាលរហោឋាន មានតែខ្យល់បក់និងព្យុះខ្សាច់។ បាប៊ីឡូនបានដួលរលំនិងមិនអាចងើបឡើងវិញក៏ពិតមែន ប៉ុន្តែកេរ្តិ៍ឈ្មោះរបស់វាស្ថិតស្ថេរព្រោះ **ចំណេះដឹង** ដែលក្រុងនេះបន្សល់ទុក ត្រូវបានរក្សារហូតដល់បច្ចុប្បន្ន ដូច្នេះហើយទើបយើងខិតខំចងក្រងជាឯកសារនេះឡើងវិញ។

ដោយសារកាលពីរាប់ពាន់ឆ្នាំមុន ក្រដាសនៅមិនទាន់ត្រូវបានគេបង្កើតនៅឡើយ ពួកគេប្រើប្រាស់បន្ទះដីឥដ្ឋសើមដើម្បីកត់ត្រា។ ពេលណាសរសេរចប់គេយកបន្ទះដីឥដ្ឋនោះទៅដុតឲ្យក្លាយជាបន្ទះឥដ្ឋរឹងមាំ។ វាមានទទឹងប្រវែងជាង ១៥cm និងបណ្តោយ ប្រហែល ២០cm និងមានកម្រាស់ ប្រហែល ២cm ។

នៅសម័យនោះ បន្ទះដីឥដ្ឋត្រូវបានគេប្រើប្រាស់ជាផ្លូវការ ដូចក្រដាសយើងប្រើនៅក្នុងសម័យបច្ចុប្បន្នដែរ។ គេប្រើវាដើម្បីសរសេររឿងព្រេង កំណាព្យ ប្រវត្តិសាស្ត្រ ព្រះរាជក្រឹត្យ ច្បាប់ សំបុត្រសម្គាល់ទ្រព្យសម្បត្តិ កិច្ចសន្យា និង សំបុត្រដែលត្រូវផ្ញើទៅកាន់ទីកន្លែងឆ្ងាយៗ។ ដោយសារបន្ទះដីឥដ្ឋទាំងនេះហើយ ទើបយើងអាចដឹងច្រើនអំពីរបៀបធ្វើទំនាក់ទំនង និង អាកប្បកិរិយារបស់មនុស្សនៅក្នុងទីក្រុងមួយនេះ។ ឧទាហរណ៍ នៅលើបន្ទះដីឥដ្ឋមួយមានសរសេរថា “ មានពេលមួយនោះ អតិថិជនម្នាក់បាននាំគោមួយក្បាលដើម្បីដូរយកស្រូវសាលីចំនួនប្រាំពីរបាវ។ បីបាវត្រូវបានគេឲ្យភ្លាមៗ ហើយបួនបាវទៀតត្រូវគេបញ្ជូនមកឲ្យនៅពេលណាដែលអតិថិជននោះត្រូវការ ” ។

**លើ**លោកនេះ លុយគឺជាឧបករណ៍សម្រាប់វាស់ភាពជោគជ័យ
**មាន**លុយគឺមានសម្បត្តិលោកិយ
**លុយ**មិនខ្វះទេសម្រាប់ជនណាដែលដឹងពីរូបមន្តរកលុយ
**រូប**មន្តរកលុយនៅសម័យបច្ចុប្បន្ន គឺមិនខុសពីរូបមន្តដែលពួកអភិជនប្រើនៅសម័យបាប៊ីឡូន កាលពី ៦០០០ឆ្នាំមុនទៀ្បយ

# បុរសដែលចង់បានមាស

« **កិច្ច**ការទាំងឡាយ បើយើងប្រឹងហើយប្រឹងទៀត ឲ្យអស់ពីសមត្ថភាព យើងប្រាកដជាជោគជ័យ »

**ប៊ែន**ហ្សៀ (Bansir) ជាងធ្វើរទេះសេះម្នាក់នៅបាប៊ីឡូន អស់សង្ឃឹមក្នុងជីវិត។ ព្រឹកនេះគាត់អង្គុយតែម្នាក់ឯងនៅលើរបងផ្ទះ ភ្នែកសម្លឹងដោយទឹកមុខក្រៀមក្រំ ទៅផ្ទះកំសត់របស់ខ្លួននិងរោងជាង ដែលមានរទេះសេះមួយនៅមិនទាន់ធ្វើរួចនៅឡើយ។

ភរិយារបស់ ប៊ែនហ្សៀ ដើរចេញចូលផ្ទះតាមទ្វារមុខជាញឹកញាប់។ នាងតែងលួចសំឡឹងមកគាត់ ជាសញ្ញាបង្ហាញថាអង្ករក្នុងក្រឡជិតអស់ហើយ ដូច្នេះគាត់ត្រូវខំប្រឹងធ្វើរទេះមួយនេះឲ្យឆាប់ចប់។ ដើម្បីបានរទេះសេះមួយ ប៊ែនហ្សៀ ត្រូវធ្វើកិច្ចការជាច្រើនដូចជា កាប់ ចាំង ដំ ប៉ូលា លាបថ្នាំ និងកិច្ចការផ្សេងៗទៀត មុននឹងអាចបញ្ជូនវាទៅឲ្យអតិថិជនបាន។

ទោះបីជា ប៊ែនហ្សៀ ត្រូវប្រញាប់ធ្វើរទេះមួយនេះឲ្យបានឆាប់ បុរសសាច់ដុំធំៗម្នាក់នេះបែរជាអង្គុយធ្វើប្រងើយនៅលើរបងផ្ទះទៅវិញ។ ចិត្តរបស់គាត់កំពុងតែអណ្តែតអណ្តូងដោយសារបញ្ហាមួយដែលនៅមិនទាន់រកចម្លើយឃើញនៅឡើយ។ ចំណែកឯព្រះអាទិត្យវិញ ចេះតែរះខ្ពស់ឡើងៗដោយគ្មានបង្អង់ ធ្វើឲ្យគ្រាប់ញើសតូចៗចាប់ផ្តើមលេចចេញមកលើថ្ងាសរបស់ ប៊ែនហ្សៀ ហើយក៏ហូរចុះចូលទៅក្នុងអាវរបស់គាត់។

ទៅមុខបន្តិចមិនឆ្ងាយប៉ុន្មាន មានជញ្ជាំងមួយខ្ពស់ត្រដែត វាគឺជញ្ជាំងព្រះបរមរាជវាំង ហើយនៅមិនឆ្ងាយពីវាំង នៅមានវិហារមួយលាបថ្នាំពណ៌ល្អឆើតឆាយ គេហៅវាថា **ព្រះវិហារ ប៊ែល** (Temple of Bell) ។ នៅក្រោមស្រមោលនៃ

សំណង់ដ៏ខ្ពស់ស្កឹមស្កៃទាំងនេះគឺផ្ទះដ៏កំសត់របស់គាត់ និងផ្ទះតូចៗជាច្រើនទៀត ដែលមើលទៅគ្មានផ្ទះមួយណាល្អជាងផ្ទះមួយណាឡើយ។ នេះជាទិដ្ឋភាពនៅក្រុងបាប៊ីឡូន គឺចំរុះគ្នារវាងសំណង់ស្កឹមស្កៃនិងសំណង់អាណាធិបតេយ្យ រវាងអ្នកមានកប់ពពកនិងអ្នកក្រហែមរហាម ដែលរស់នៅជាមួយគ្នានៅក្នុងជញ្ជាំងទីក្រុង ដោយគ្មានបែងចែងជាខ័ណ្ឌឬតំបន់ឡើយ។

នៅខាងក្រោយខ្នងរបស់ ប៊េនហ្សៀ មានសម្លេងរទេះសេះរបស់ពួកអភិជនកំពុងបរទៅវិញទៅមកនៅលើដងផ្លូវដែលខ័ណ្ឌចែកដាច់ពីគ្នារវាងមនុស្សពីរក្រុម ដែលនៅម្ខាងផ្លូវគឺក្រុមអ្នកលក់ដូរ និង នៅម្ខាងទៀតគឺក្រុមអ្នកសុំទាន។ ក៏នៅមានសម្លេងរបស់ទាសករយ៉ាងច្រើនកុះករ កំពុងដើរជាជួរយ៉ាងវែង ធ្វើការបម្រើព្រះរាជា ដោយជញ្ជូនទឹកពីទន្លេទៅស្រោចសួនច្បារព្រះបរមរាជវាំង ហើយសូម្បីតែអ្នកមានៗក៏ត្រូវគេបង្ខំឲ្យចៀសដើម្បីទុកផ្លូវឲ្យទាសករទាំងនោះដើរដែរ ។

ប៊េនហ្សៀ ដែលកំពុងតែស្លុងក្នុងអារម្មណ៍របស់ខ្លួន មិនបានឮ ឬខ្វល់ខ្វាយនឹងសម្លេងកងរំពងរបស់ទីក្រុងដ៏មមាញឹកនោះឡើយ។ ប៉ុន្តែមានសម្លេងយ៉ាងក្រលួច ដូចជាសម្លេងខ្សែពិណបុរាណមួយ មកកន្ត្រាក់ស្មារតីរបស់គាត់ឲ្យភ្ញាក់ឡើង។ ប៊េនហ្សៀ បែរខ្លួនក៏ឃើញមិត្តចាស់ឈ្មោះ កូប៊ី( Kobbi ) ដែលជាតន្ត្រីករ កំពុងឈរញញឹមដាក់គាត់។

“ សូមឲ្យទេវតាតាមជួយថែរក្សាឯង, សម្លាញ់ ! ” កូប៊ី និយាយដោយពាក្យគួរសម “ ទ្រង់ប្រាកដជានាំមកនូវសំណាងល្អ ព្រោះទ្រង់មានទឹកព្រះទ័យមេត្តា ករុណា ដូច្នេះឯងមិនចាំបាច់ខំប្រឹងធ្វើការខ្លាំងពេកទេ។ នែ៎.. ខ្ញុំ មានលាភធំមួយមកចែក។ លាភនេះនឹងធ្វើឲ្យកាបូបរបស់ឯងឡើងប៉ោងមិនខាន ពេលនោះឯងមិនចាំបាច់អស់កម្លាំងធ្វើការក្នុងរោងជាងទៀតទេ។ ឥលូវឲ្យខ្ញុំខ្ចីប្រាក់ពីរកាក់សិនមក តែពីរទេ ខ្ញុំនឹងសងវិញបន្ទាប់ពីលេងតន្ត្រីនៅក្នុងពិធីបុណ្យរបស់ពួកគហបតីនៅយប់នេះ។ ឯងកុំខ្លាចអី នៅពេលសង ខ្ញុំឲ្យថ្លៃការប្រាក់បន្ថែមលើប្រាក់របស់ឯង ! ”

“ បើខ្ញុំមានប្រាក់ពីរកាក់ក្នុងកាបូបមែន ” បេនហ្សៃ និយាយក្នុងទឹកមុខស្ងួត “ រឿនអីត្រូវឲ្យគេខ្ចី សូម្បីឯងក៏ខ្ញុំមិនឲ្យខ្ចីដែរ។ គ្មានអ្នកណាល្ងង់ឲ្យប្រាក់ដែលខ្លួនមានឲ្យគេខ្ចីទាំងអស់ទេ ស្និទ្ធស្នាលយ៉ាងណាក៏ទៅមិនរួចដែរ! ” ។

“ ថាម៉េច ! ” កូប៊ី លាន់មាត់ “ ឯងអត់មានប្រាក់ក្នុងកាបូបសូម្បីតែមួយកាក់! ចុះហេតុអីក៏អង្គុយធ្វើមើហ៍តែរូបចម្លាក់មិនធ្វើការអីសោះអញ្ចឹង! ម៉េចក៏មិនធ្វើរទេះឲ្យឆាប់ហើយទៅ? ក្រៅពីធ្វើរទេះ ឯងមានអីដើម្បីដោះដូរនឹងពួកអ្នកមានបាន? ឯងមិនធ្លាប់ធ្វើបែបនេះទេសម្លាញ់! តើថាមពលរបស់ឯងបាត់ទៅណាអស់ហើយ? ស្អីគេដែលធ្វើឲ្យឯងពិបាកចិត្តយ៉ាងហ្នឹង? ទេព្តាដាក់បណ្តាសាឯងមែនទេ ? ”

“ ប្រហែលជាទេព្តាដាក់ទណ្ឌកម្មខ្ញុំហើយ! ” បេនហ្សៃ រអ៊ូ “ គឺស្រមើស្រមៃ ស្រមៃមិនចេះចប់ ខ្ញុំស្រមៃចង់ក្លាយជាមនុស្សមានន័យខ្លឹមសារនឹងគេម្នាក់។ ខ្ញុំស្រមៃថាមានប្រាក់ជាច្រើននៅក្នុងកាបូប ដូច្នេះខ្ញុំអាចដាក់ទាន ខ្ញុំអាចទិញរបស់មានតម្លៃឲ្យប្រពន្ធនិងខ្លួនឯង។ ពេលខ្ញុំមានប្រាក់ច្រើន ខ្ញុំមិនបារម្ភនឹងការចាយវាយ និងមិនបារម្ភអំពីថ្ងៃអនាគត។ អារម្មណ៍នេះធ្វើឲ្យចិត្តរបស់ខ្ញុំរអើរវាយរហូត! ឯងក៏ដឹងស្រាប់ហើយថាខ្ញុំប្រឹងធ្វើការប៉ុណ្ណា ឯប្រពន្ធរបស់ខ្ញុំក៏អញ្ចឹងដែរ ខំធ្វើការរហូតលែងខ្វល់នឹងមុខមាត់របស់ខ្លួនទៅហើយ ” ។

“ ជក់ចិត្តមែន! ” កូប៊ី និយាយ “ ប៉ុន្តែអ្វីដែលធ្វើឲ្យឯងស្រមៃរហូតដល់ក្លាយជារូបចម្លាក់ អង្គុយផ្ទឹងលើរបងបែបនេះ? ”

“ គឺឲ្យតែភ្ញាក់ឡើងពេលណា ខ្ញុំនឹកឃើញមុនគេគឺកាបូបអត់ប្រាក់នឹងតែម្តង វាធ្វើឲ្យអារម្មណ៍ច្របូកច្របល់រត់ពេញខួរក្បាលរបស់ខ្ញុំ។ តោះជជែកគ្នារឿងនេះបន្តិច ព្រោះយើងទាំងពីរនាក់មានបញ្ហាដូចគ្នា។ កាលនៅក្មេង យើងទៅរៀនអក្សរជាមួយគ្នា។ នៅពេលដល់វ័យជំទង់ យើងដើរលេងជាមួយគ្នា។ នៅពេលចាស់ឡើង យើងនៅតែជាមិត្តសម្លាញ់នឹងគ្នាដដែល។ យើងស្រលាញ់ការងារខ្លួនឯង និងខំប្រឹងធ្វើការច្រើនម៉ោងថែមទៀតផង ហើយពេលរកប្រាក់បាន

ក៏ចាយវាយដោយសេរីថែមទៀត។ ច្រើនឆ្នាំមកនេះយើងរកបានប្រាក់ច្រើនដែរ តែឥលូវអត់សល់សោះ អញ្ចឹងដើម្បីឲ្យសប្បាយចិត្តមានតែអង្គុយស្រមៃ។ និយាយទៅ យើងល្ងង់ជាងសត្វចៀមទៅទៀត មែនទេ ? យើងរស់នៅក្នុងទីក្រុងដែលស៊ីវិល្ស និងសម្បូរសប្បាយជាងគេនៅលើលោក។ អ្នកដែលធ្វើដំណើរផ្លូវឆ្ងាយៗ តែងនិយាយថា គ្មានកន្លែងណាដែលសម្បូរសប្បាយដូចទីក្រុងបាប៊ីឡូននេះទេ។ ចំណែកយើងវិញ អង្គុយតែសរសើរគេដែលមានទ្រព្យសម្បត្តិច្រើន តែខ្លួនឯងវិញគ្មានអីទេ។ ធ្វើការជិតពាក់កណ្ដាលជីវិតទៅហើយ កាបូបនៅតែស្អាតដដែល ហើយឥលូវឯងមកនិយាយ « អាចឲ្យអញខ្ចីប្រាក់ពីរកាក់សិន និងសងវិញបន្ទាប់ពីបុណ្យយប់នេះ » អត់មានទេ! និយាយស្មោះ កាបូបគ្នាក៏ទទេដែរ ។ ហេតុអ្វីបានជាអញ្ចឹង? ហេតុអីយើងមិនអាចរកមាសប្រាក់ឲ្យបានច្រើនជាងចំណាយលើអាហារនិងសម្លៀកបំពាក់បាន? ”

“ គិតពីកូនៗរបស់យើងវិញ ” ប៊េនហ្សៀ និយាយត “ ឯងអត់យល់ថាពួកគេកំពុងតែដើរតាមផ្លូវរបស់យើងទេអី? ពួកគេ គ្រួសារ ព្រមទាំងចៅៗរបស់ពួកគេ បានរស់នៅក្នុងក្រុងដែលជាឃ្លាំងមាសឃ្លាំងប្រាក់ទៅហើយ តែបែរជាដូចយើងអញ្ចឹង មួយថ្ងៃៗស៊ីតែបបរ និងផឹកទឹកដោះពពែជូរ ” ។

“ ប្លែកមែន! ប្លែកមែន ! តាំងពីបានស្គាល់ឯងមក ខ្ញុំមិនដែលឮឯងនិយាយបែបនេះសោះ ប៊េនហ្សៀ ” កូប៊ី និយាយបែបឆ្ងល់។

“ ពីមុនខ្ញុំមិនដែលគិតបែបនេះមែន។ តាំងពីព្រឹករហូតដល់យប់ ខ្ញុំខំប្រឹងធ្វើរទេះសេះដោយផ្ចិតផ្ចង់បំផុត សង្ឃឹមថាថ្ងៃណាមួយទេព្ដាមើលឃើញសេចក្ដីល្អនេះ និងប្រទានពរដល់ខ្ញុំឲ្យក្លាយជាអ្នកមានម្នាក់នឹងគេ ប៉ុន្តែទេព្ដាមើលមិនឃើញទេ។ ហើយឥលូវ ខ្ញុំយល់ថាគ្មានថ្ងៃណាដែលទេព្ដាជួយខ្ញុំឡើយ ដូច្នេះហើយទើបខ្ញុំខ្វល់ក្នុងចិត្ត។ ខ្ញុំតែងប្រាថ្នាចង់ក្លាយជាមនុស្សម្នាក់មានន័យខ្លឹមសារក្នុងជីវិត។ ខ្ញុំចង់មានដី ចង់មានគោ ចង់មានសម្លៀកបំពាក់ល្អៗ និង ចង់មានប្រាក់ច្រើននៅក្នុងកាបូប។ ខ្ញុំមិនខ្លាចការងារទេ ខ្ញុំអាចធ្វើការដោយមិនខ្លាច

នឿយហត់ ធ្វើការឲ្យអស់ពីជំនាញដែលខ្ញុំមាន ធ្វើការឲ្យអស់ពីកម្លាំងបញ្ញានិងស្មារតី ប៉ុន្តែសូមតែម្យ៉ាង សូមឲ្យផលទទួលបានសាកសមនឹងអ្វីដែលខ្ញុំលះបង់។ ប៉ុន្តែខ្ញុំឆ្ងល់ណាស់ ហេតុអីបានជាបញ្ហាទាំងអស់នេះធ្លាក់មកលើយើង? ឥលូវខ្ញុំសួរឯងវិញម្តង! របស់ល្អៗមានច្រើនហូរហៀរពាសពេញក្រុង ចុះហេតុអីបានជាយើងគ្មាន ហើយមានតែអ្នកមានប្រាក់ មានមាស តែប៉ុណ្ណោះដែលអាចទិញរបស់ទាំងនោះបាន? "

" ធ្វើម៉េចខ្ញុំដឹងទៅ? " កូប៊ី ឆ្លើយ " ខ្ញុំក៏មិនគ្រាន់បើជាងឯងប៉ុន្មានដែរ។ ប្រាក់ខ្ញុំរកបានពីការលេងពិណ ត្រូវចាយអស់មួយរំពេច។ ខ្ញុំមានផែនការណ៍តែមួយគត់ គឺត្រូវធ្វើយ៉ាងណាកុំឲ្យគ្រួសារខ្ញុំដាច់បាយទៅបានហើយ។ ដូចឯងអញ្ចឹង ខ្ញុំគ្មានចេះអ្វីក្រៅពីលេងពិណទេ ព្រោះនៅក្នុងខួរក្បាលរបស់ខ្ញុំមានតែសម្លេងពិណ។ មានពិណមួយនេះ ខ្ញុំអាចដេញតន្ត្រីពីរោះបំផុត សូម្បីតែស្តេចក៏មិនធ្លាប់បានស្តាប់ដែរ " ។

" ឯងអាចធ្វើរទេះសេះបានល្អគ្មាននរណាប្រៀប ហើយក៏គ្មាននរណាម្នាក់នៅបាប៊ីឡូនអាចធ្វើពិណល្អបែបនេះដែរ។ ពិណនេះមានសម្លេងពីរោះណាស់ កុំថាឡើយស្តេច សូម្បីតែទេព្តាក៏សប្បាយចិត្តបើបានស្តាប់សម្លេងរបស់វា។ ប៉ុន្តែយើងទាំងពីរនាក់នៅតែក្រដូចជាទាសកររស្តេចដដែល។ ឈប់ៗ ស្តាប់សម្លេងកណ្តឹងសិន! " កូប៊ី ចង្អុលទៅហ្វូងទាសករកំពុងជញ្ជូនទឹកឡើងតាមផ្លូវតូចមួយពីមាត់ទន្លេ។ ពួកគេគ្មានអាវពាក់និងដើរជាក្រុមប្រាំៗនាក់ ដៃខំប្រឹងកាន់ស្បែកពពែដែលមានទឹកពេញ។

" ម្នាក់ដើរនៅខាងមុខគឺជាមេដឹកនាំគេ " កូប៊ី សំដៅលើអ្នកវាយកណ្តឹងដែលកំពុងដើរនៅមុខអ្នកយួរទឹក។ " មេដឹកនាំជាអ្នកលេចធ្លោជាងគេនៅក្នុងក្រុមហើយងាយសម្គាល់ណាស់ " ។

" មែនហើយ មានទាសករខ្លះជាមនុស្សល្អ " ប៉េនហ្សៀ និយាយ " ពួកគេមើលទៅដូចជាមិនខុសអីពីយើងផង ៖ អ្នកមាឌខ្ពស់ សក់ពណ៌មាស គឺ

មកពីតំបន់ភាគខាងជើង អ្នកដែលមានសំបុរខ្មៅគឺមកពីភាគខាងត្បូង ហើយអ្នកមានមាឌល្អិត សំបុរសណ្តែកបាយ គឺមកពីតំបន់ក្បែរៗក្រុង។ ពួកគេដើរជាជួរៗជញ្ជូនទឹកពីទន្លេទៅស្រោចសួនព្រះបរមរាជវាំងរាល់ថ្ងៃនិងរាល់ឆ្នាំ។ មើលទៅពួកគេក៏មិនសប្បាយចិត្តដែរ។ ដេកលើចំបើងនិងស៊ីបបរជាអាហារ។ គួរឲ្យអាណិតណាស់ ដូចសត្វតិច្ឆានអញ្ចឹង មែនទេ កូប៊ី ? ”

“ ខ្ញុំក៏អាណិតពួកគេដែរ ប៉ុន្តែខ្ញុំយល់ថា ការពិតទៅយើងក៏មិនគ្រាន់បើជាងពួកគេប៉ុន្មានទេ ទោះយើងមិនមែនជាទាសករក៏ដោយ ” ។

“ ត្រូវហើយ កូប៊ី ។ យើងមិនអាចទ្រាំរស់នៅពីមួយឆ្នាំទៅមួយឆ្នាំដូចជាទាសករបែបនេះតទៅទៀតទេ ៖ ធ្វើការ ធ្វើការ ធ្វើការ តែគ្មានសល់អីសោះ ” ។

“ អញ្ចឹងយើងគួរតែរកមើលនរណាគេអាចរកមាសបានច្រើន បន្ទាប់មកយើងរៀនតាមគាត់ដែលទៅ យ៉ាងម៉េចដែរ ? ” កូប៊ី បញ្ចេញយោបល់

“ មែនហើយ ប្រហែលមានអាថ៌កំបាំងណាមួយដែលយើងត្រូវរៀនដើម្បីអាចក្លាយជាអ្នកមានម្នាក់បាន។ ខ្ញុំយល់ថា យើងត្រូវរៀនពីមនុស្សដែលបានដឹងពីអាថ៌កំបាំងនេះ ” បេនហ្សៀ និយាយបែបជឿជាក់ ។

“ ថ្ងៃមុន ” កូប៊ី និយាយត “ ខ្ញុំបានឃើញមិត្តចាស់ម្នាក់ឈ្មោះ អាខេដ (Arkad) កំពុងជិះលើរទេះមាសរបស់គាត់។ ខ្ញុំគិតថាប្រហែលជាគាត់ធ្វើមិនឃើញខ្ញុំទេ តែផ្ទុយមកវិញគាត់បានលើកដៃគ្រវី បង្ហាញការគោរពនិងសេចក្តីរាប់អានដល់រូបខ្ញុំ កូប៊ី ”

“ គេហៅគាត់ថាជាកំពូលអ្នកមាននៅបាប៊ីឡូននេះ ” បេនហ្សៀ និយាយបែបសញ្ជឹងគិត

“ មានខ្លាំងណាស់! សូម្បីតែព្រះរាជាក៏ត្រូវការឲ្យគាត់ជួយឧបត្ថម្ភដើម្បីចំណាយលើកិច្ចការក្នុងព្រះរមរាជវាំងដែរ ” កូប៊ី និយាយ។ “ មានដំម្លឹងផង! ” បេនហ្សៀ និយាយកាត់ “ ប្រសិនជាខ្ញុំជួបគាត់នៅកណ្តាលយប់ស្ងាត់ ខ្ញុំខ្លាចតែ

មិនអាចទប់ចិត្តខ្លួនឯងកុំឲ្យកញ្ឆក់យកកាបូបដ៏ធាត់ទ្រលុកទ្រលន់របស់គាត់បានទេមើលទៅ ! ”

“ ល្ងង់មែន ” កូប៊ី បន្ទោស “ ទ្រព្យសម្បត្តិរបស់អ្នកមានមិនមែនទុកនៅក្នុងកាបូបដែលគាត់យួរតាមខ្លួននោះទេ ។ កាបូបធាត់យ៉ាងណាក៏ដោយ ក៏គង់អស់ប្រាក់រលីងដែរ ប្រសិនបើគ្មានប្រាក់ហូរចូលជាប្រចាំទេនោះ។ អាខេដ មានចំណូលហូរចូលជាប្រចាំ ធ្វើឲ្យកាបូបរបស់គាត់ធាត់ទៅៗ ទោះបីជាគាត់ចាយយ៉ាងណាក៏មិនអស់ដែរ ”

“ ចំណូលហ្នឹងហើយ! ” បេនហ្សៀ ភ្ញាក់ផ្អើល “ ខ្ញុំចង់បានចំណូលហូរចូលក្នុងកាបូបរបស់ខ្ញុំជាប្រចាំ ទោះបីជាខ្ញុំអង្គុយលេង ឬដើរលេងនៅទីឆ្ងាយក៏ដោយ ។ អាខេដ ច្បាស់ជាដឹងអាថ៌កំបាំងដែលធ្វើឲ្យមនុស្សម្នាក់អាចមានចំណូលបែបហ្នឹងមិនខាន។ គាត់ប្រាកដជាអាចធ្វើឲ្យមនុស្សដែលខួរក្បាលដើរយឺតដូចជាខ្ញុំភ្លឺស្វាងឡើងវិញ ” ។

“ អាខេដ បានបង្រៀនចំណេះដឹងនេះទៅកូនរបស់គាត់ឈ្មោះណូម៉ាហ្សៀ(Nomasir) ” កូប៊ី ឆ្លើយតប “ ខ្ញុំឮគេនិយាយថាគាត់បានបញ្ជូនណូម៉ាហ្សៀ ទៅកាន់ទីក្រុង នីននីវី (Nineveh) ក្រោយមក ណូម៉ាហ្សៀ ក៏បានក្លាយជាអ្នកមានបំផុតម្នាក់នៅទីក្រុងនោះ ” ។

“ កូប៊ី ឯងធ្វើឲ្យខ្ញុំនឹកឃើញគំនិតមួយ ” ពន្លឺនៃក្តីសង្ឃឹមថ្មីបានលេចចេញក្នុងកែវភ្នែករបស់ បេនហ្សៀ “គ្រាន់តែសួរសុំយោបល់ពីមិត្តល្អម្នាក់ វាគ្មានទៅអស់ស្អីទេ ហើយណាមួយ អាខេដ ក៏ជាមនុស្សចិត្តទូលាយដែរ។ ឥលូវខ្ញុំយល់ហើយថា ទោះបីជាកាបូបយើងទទេស្អាតដូចសំបុកសត្វក៏ដោយក៏មិនអីដែរ កុំចាត់ទុកវាជាឧបសគ្គរបស់យើងទៀតអី។ យើងឆ្អែតនឹងជីវិតដែលបានរស់នៅលើចំការមាសចំការប្រាក់ទៅហើយ តែកាបូបបែរជាទទេស្អាត។ យើងគួរតាំងចិត្តចង់ក្លាយជាមនុស្សដែលមានន័យខ្លឹមសារក្នុងជីវិតដូចគេ។ តោះ! យើងទៅរកអាខេដ និងសួរគាត់ តើយើងគួរធ្វើយ៉ាងម៉េចដើម្បីបង្កើនប្រាក់ចំណូលបាន ” ។

“ ប៊ែនហ្សៃ ! ឯងនិយាយបែបហ្នឹងធ្វើឲ្យខ្ញុំមានកម្លាំងចិត្តណាស់។ សម្ដីរបស់ឯងដូចជាដាស់ខ្ញុំឲ្យភ្ញាក់ពីដេកអញ្ចឹង។ ឯងធ្វើឲ្យខ្ញុំដឹងពីមូលហេតុដែលធ្វើឲ្យយើងក្រ គ្មានទ្រព្យសម្បត្តិច្រើនដូចគេ។ ខ្ញុំមិនដែលបានគិតពីបញ្ហានេះសោះពីមុនមក។ ឯងព្យាយាមធ្វើរទេះសេះដោយស្មោះត្រង់យូរមកហើយ។ ព្រោះតែចង់ការពារចិត្តទៀងត្រង់ ឯងខំប្រឹងធ្វើដោយផ្ចិតផ្ចង់បំផុត។ ដូច្នេះទើបឯងអាចធ្វើរទេះល្អបំផុតនៅបាប៊ីឡូននេះ ហើយជំនាញធ្វើរទេះនឹងធ្វើឲ្យឯងជោគជ័យ។ ចំណែកខ្ញុំស្រលាញ់ខាងតន្ត្រី និងចង់ក្លាយជាលេងពិណយ៉ាងជំនាញម្នាក់ ហើយការព្យាយាមរបស់ខ្ញុំក៏នឹងធ្វើឲ្យខ្ញុំជោគជ័យដែរ ” ។

“ **កិច្ចការទាំងឡាយ បើយើងប្រឹងហើយប្រឹងទៀត ឲ្យអស់ពីសមត្ថភាពយើងប្រាកដជាជោគជ័យ**។ ទេព្ដាច្បាស់ជាពេញចិត្តនឹងការព្យាយាមរបស់យើង។ ទីបញ្ចប់យើងបានរកឃើញពន្លឺហើយ គឺពន្លឺដែលធ្វើឲ្យយើងភ្លឺភ្នែកដូចព្រះអាទិត្យដែលកំពុងរះអញ្ចឹង។ ខ្ញុំយល់ថា «**បើយើងចេះកាន់តែច្រើន យើងកាន់តែមាន**»។ ឥលូវយើងត្រូវរកវិធីល្អណាមួយដែលខុសពីវិធីដែលយើងប្រើរាល់ថ្ងៃដើម្បីទទួលបានជោគជ័យដែលយើងប្រាថ្នា ” ។

“ តោះ! យើងទៅរក អាខេដ ថ្ងៃនេះតែម្ដង” ប៊ែនហ្សៃ ទទូច “ ហើយយើងគួរនាំមិត្តភក្តិដែលមានជីវភាពលំបាកដូចគ្នាទៅជួប អាខេដ ដើម្បីទទួលបានការណែនាំពីគាត់ទាំងអស់គ្នា ” ។

“ ឯងចេះគិតគូរដល់មិត្តភក្ដិមែន ប៊ែនហ្សៃ ។ ដូច្នេះនាំមិត្តភក្តិរបស់ឯងឲ្យច្រើនមក ហើយទៅជួប អាខេដ នៅថ្ងៃនេះតែម្ដង ” ។

## **ចេះ**កាន់តែច្រើន យើងកាន់តែមាន

# កំពូលអ្នកមាននៅក្រុង បាប៊ីឡូន

« **ជោគ**ជ័យ ត្រូវការរបស់ពីរជាចាំបាច់គឺ **ពេលវេលា** និង **ចំណេះដឹង** »

**នៅ**ក្រុងបាប៊ីឡូនមានមហាសេដ្ឋីម្នាក់ឈ្មោះ អាខេដ ដែលមនុស្សជិតឆ្ងាយទទួលស្គាល់ថាជាកំពូលអ្នកមានទ្រព្យសម្បត្តិច្រើនលើសគេ តែគាត់ជាមនុស្សចិត្តល្អនិងចិត្តទូលាយ។ គាត់ចូលចិត្តដាក់ទាន ហើយក៏ជាមនុស្សចិត្តធម៌ម្នាក់នៅក្នុងគ្រួសារដែរ។ តាមពិតគាត់ចំណាយច្រើនណាស់ដែរ ប៉ុន្តែមិនដឹងជាយ៉ាងម៉េចទ្រព្យសម្បត្តិរបស់គាត់ចេះតែច្រើនឡើងៗ ។

ថ្ងៃនេះមានមិត្តភក្តិមួយចំនួនមកលេង និងសួរគាត់ថា “ អាខេដ លោកមានទ្រព្យសម្បត្តិច្រើនជាងយើងសរុបចូលគ្នាទៅទៀត។ ក្នុងពេលមនុស្សភាគច្រើនខំប្រឹងធ្វើយ៉ាងណាចិញ្ចឹមក្រពះឲ្យតែរស់ តែលោកបែរជាក្លាយជាអ្នកមានជាងគេនៅបាប៊ីឡូននេះទៅវិញ ។ លោកមានសម្លៀកបំពាក់ល្អៗ មានអាហារឆ្ងាញ់ៗដែលកម្របានឃើញ ចំណែកពួកយើងវិញឲ្យតែបានបាយហូបគ្រប់គ្រាន់និងមានសម្លៀកបំពាក់សមរម្យ គឺពេញចិត្តណាស់ទៅហើយ ” ។

“ កាលពីមុនយើងគឺដូចតែគ្នាសោះ ។ យើងរៀនពីគ្រូតែមួយ ។ យើងលេងកីឡាជាមួយគ្នា ។ ទាំងរៀន ទាំងលេងកីឡា លោកមិនពូកែជាងយើងទេ។ កាលណោះ លោកក្រ និង មិនមានកិត្តិយស ដូចជាពួកយើងផង ” ។

“ ហើយយើងកត់សម្គាល់ឃើញថា លោកដូចជាមិនសូវខំប្រឹងធ្វើការណាស់ណាទេ។ ឥលូវ តើសំណាងអីធ្វើឲ្យជីវិតលោកលេចអណ្តែត ចំណែកឯពួកយើងវិញ ដែលយល់ថាសមនឹងទទួលបានសំណាងបែបហ្នឹងព្រោះខំប្រឹងធ្វើការមិនហ៊ានឈប់ បែរជាអត់បានទៅវិញ ? ”

ពេលនោះ អាខេដ និយាយ “ អ្នកទាំងអស់គ្នារកបានតែមួយក្រពះៗ

ពីព្រោះច្រើនឆ្នាំមកនេះអ្នកទាំងអស់គ្នាមិនព្រមរៀនពីក្បួនរកលុយ ឬក៏ប្រហែលជាចេះក្បួនហ្នឹងដែរ តែមិនព្រមអនុវត្តតាមវា ”។

“ **សំណាង** គឺដូចជារបស់អាក្រក់មួយអញ្ចឹង វាមិនដែលនាំសេចក្តីសុខដល់នរណាម្នាក់បានមួយជីវិតនោះទេ។ ផ្ទុយទៅវិញ វាបែរជាធ្វើឲ្យពួកគេអន្តរាយទៅវិញក៏ថាបាន ព្រោះថា **ប្រាក់ដែលបានមកដោយងាយ គ្មានបញ្ចេញកម្លាំងញើសឈាម អស់ទៅវិញក៏ងាយដែរ**។ អ្នកបានប្រាក់ដោយសារសំណាងនឹងចាយវាយមិនសំចៃ ហើយមួយប៉ប្រិចភ្នែក ប្រាក់នោះនឹងបាត់ទៅវិញអស់គ្មានសល់អ្វីក្រៅតែអំពីសេចក្តីស្រេកឃ្លានដែលពួកគេគ្មានសមត្ថភាពរកអ្វីដើម្បីមកបំពេញតទៅទៀតបាន ហើយអ្នកមានទ្រព្យសម្បត្តិកើតចេញពីសំណាងក៏នឹងក្លាយជាមនុស្សកំណាញ់ ខំលាក់ទ្រព្យសម្បត្តិទុកមិនហ៊ានចាយ ព្រោះពួកគេដឹងច្បាស់ថាខ្លួនឯងគ្មានសមត្ថភាពរកប្រាក់។ ដូច្នេះពួកគេកាន់តែព្រួយបារម្ភព្រោះខ្លាចគេលួច ធ្វើឲ្យខ្លួនឯងកាន់តែវេទនាទៅៗ រស់ក្នុងជីវិតគ្មានន័យ និងបៀមសេចក្តីទុក្ខរាល់ថ្ងៃ ”។

“ មែនហើយ ប្រហែលមានមនុស្សមួយចំនួនបានយកប្រាក់ដែលទទួលមកដោយសំណាងទៅរកស៊ី ធ្វើឲ្យខ្លួនកាន់តែមានទៅៗនាំឲ្យជីវិតមានសេចក្តីសុខសប្បាយ ប៉ុន្តែមនុស្សប្រភេទនេះមានតិចតួចណាស់។ ឧទាហរណ៍បើអ្នកទាំងអស់គ្នានៅសុខៗ ដុំមាសស្រាប់តែធ្លាក់មកក្នុងដៃ ពេលនោះរឿងអាក្រក់ទាំងអស់នេះប្រាកដជាធ្លាក់មកលើខ្លួនជាក់ជាមិនខាន ”។

មិត្តរបស់ អាខេដ យល់ថាគាត់និយាយត្រូវ ព្រោះពួកគេធ្លាប់ឃើញអ្នកដែលទទួលកេរ្តិ៍មរតកពីឪពុកម្តាយតែងតែជួបប្រទះរឿងទាំងអស់នោះមែន។ ពេលនោះពួកគេទទូចសុំឲ្យ អាខេដ ពន្យល់ពួកគេថាត្រូវធ្វើយ៉ាងណាដើម្បីរកប្រាក់ឲ្យបានច្រើន ដូច្នេះហើយ អាខេដ ក៏បន្ត “ កាលខ្ញុំនៅក្មេង ខ្ញុំតែងតាំងចិត្តថា **ខ្ញុំជាមនុស្សដែលមានសមត្ថភាព**។ ខ្ញុំមានសមត្ថភាពអាចចិញ្ចឹមជីវិតខ្លួនឯងឲ្យសប្បាយរីករាយនិងឲ្យគ្រប់គ្រាន់ ហើយខ្ញុំជឿថាលុយគឺកើតចេញពីការតាំង

ចិត្តនេះឯង។ លុយ គឺ ជាអំណាច ព្រោះពេលមានលុយយើងអាចធ្វើអ្វីៗផ្សេងៗទៀតបាន ” ។

“ មានលុយ យើងអាចមានផ្ទះធំស្កឹមស្កៃ និងមានគ្រឿងសង្ហារឹមល្អៗ ,
មានលុយ យើងអាចធ្វើដំណើរកំសាន្តទៅកាន់ទីឆ្ងាយៗ ,
មានលុយ យើងអាចហូបអាហារល្អៗ ប្លែកៗ មកពីតំបន់ផ្សេងៗ ,
មានលុយ យើងអាចទិញគ្រឿងតុបតែងធ្វើអំពីមាស និងថ្មមានតម្លៃ ,
មានលុយ យើងអាចកសាងវត្តអារាមសម្រាប់ជាទីសក្ការៈ ,
និងរបស់ច្រើនទៀតដែលធ្វើឲ្យជីវិតយើងរីករាយនិងមានសេចក្តីសុខ ”

“ នៅពេលខ្ញុំយល់សេចក្តីពិតនេះ ខ្ញុំក៏សម្រេចចិត្តថា ខ្ញុំក៏សាកសមនឹងទទួលបានរបស់ល្អៗសម្រាប់ជីវិតខ្លួនឯងដូចអ្នកដទៃទៀតដែរ។ ខ្ញុំមិនធ្វើដូចមនុស្សមួយចំនួនដែលចូលចិត្តអង្គុយច្រណែននឹងសុភមង្គលរបស់អ្នកដទៃនោះទេ។ ខ្ញុំមិនអាចស្អប់ស្អល់នឹងសម្លៀកបំពាក់ថោកៗ ទោះបីជាមើលទៅសមរម្យក៏ដោយ។ ខ្ញុំមិនត្រូវមានសេចក្តីគ្រប់គ្រាន់ដោយរបស់របរសម្រាប់តែអ្នកក្រប្រើប្រាស់នោះឡើយ។ ផ្ទុយទៅវិញ ខ្ញុំត្រូវធ្វើខ្លួនឯងឲ្យទៅជាម្ចាស់នៃរបស់ល្អៗ និងមានតម្លៃទាំងឡាយ ” ។

“ ដូចអ្នកទាំងអស់គ្នាបានស្គាល់ខ្ញុំច្បាស់ហើយ ខ្ញុំគ្រាន់តែជាកូនអ្នករកស៊ីតូចតាចម្នាក់ រស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើន គ្មានមរតក គ្មានវាសនាល្អ គ្មានអំណាច និងការអប់រំ ប៉ុន្តែខ្ញុំយល់ថា ដើម្បីទទួលបានជោគជ័យអ្វីដែលខ្ញុំត្រូវការជាងគេគឺ **ពេលវេលា** និង **ចំណេះដឹង** ” ។

“ បើនិយាយពី **ពេលវេលា** មនុស្សម្នាក់ៗសុទ្ធតែមាន មិនខ្វះនោះទេ។ ប៉ុន្តែបញ្ហាគឺនៅត្រង់ថាអស់លោកចេះតែបណ្តែតបណ្តោយឲ្យពេលវេលាកន្លងចោល មិនប្រើប្រាស់វាដើម្បីធ្វើខ្លួនឯងឲ្យក្លាយជាអ្នកមានម្នាក់។ តើហ៊ានទទួលស្គាល់ទេថា ក្រៅពីមានគ្រួសារល្អ អ្នកទាំងអស់គ្នាគ្មានអ្វីសោះដែលធ្វើឲ្យខ្លួន

មានមោទនភាព ? " ។

" បើនិយាយពី **ចំណេះដឹង** វិញ គ្រូរបស់យើងមិនបានបង្រៀនទេថាការពិតការរៀនមានពីរប្រភេទ ៖ ទីមួយ **គឺរៀនឲ្យដឹងអំពីអ្វីមួយដែលមានហើយស្រាប់** ឯទីពី **គឺរៀនរករបស់ដែលយើងមិនទាន់ដឹង** " ។

" អញ្ចឹងហើយទើបខ្ញុំសម្រេចចិត្តថាត្រូវរកឲ្យឃើញ **តើគេធ្វើយ៉ាងម៉េចបានជារកលុយបានច្រើន ?** នៅពេលខ្ញុំរកឃើញអាថ៌កំបាំងនេះ ខ្ញុំក៏អនុវត្តតាម ហើយខ្ញុំក៏អាចរកលុយបានច្រើនដូចគេដែរ។ បានរស់នៅក្នុងពិភពលោកដ៏ស្រស់បំព្រងទៅហើយ តែម្តងសប្បាយម្តងកើតទុក្ខ តើអស់លោកមិនយល់ថានេះមិនមែនមកពី **អវិជ្ជា** ទេអី ? "

" ការងារដំបូងរបស់ខ្ញុំគឺធ្វើជាអ្នកចម្លងអក្សរឲ្យគេ។ ខ្ញុំធ្វើការច្រើនម៉ោងជារៀងរាល់ថ្ងៃ ដោយឆ្លាក់អក្សរដាក់លើបន្ទះដីឥដ្ឋ។ ខ្ញុំប្រឹងធ្វើការពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ពីមួយខែទៅមួយខែ តែទីបញ្ចប់ខ្ញុំគ្មានសល់អ្វីសោះ ។ ចំណូលត្រូវចាយអស់លើអាហារ សម្លៀកបំពាក់ គ្រឿងសម្រាប់បូជា និង សំភារៈផ្សេងៗទៀត ប៉ុន្តែការតាំងចិត្តរបស់ខ្ញុំមិនបាត់បង់ឡើយ " ។

" ថ្ងៃមួយ អាលហ្គាមីស(Algamish) អ្នកចងការប្រាក់ បានអញ្ជើញមកហាងថៅកែខ្ញុំ ព្រោះគាត់ត្រូវការចម្លងអត្ថបទមួយច្បាប់។ គាត់និយាយជាមួយខ្ញុំថា ៖ « ខ្ញុំត្រូវការចម្លងច្បាប់នេះឲ្យហើយក្នុងរយៈពេលពីរថ្ងៃ។ បើឯងចម្លងចប់ទាន់ពេល ខ្ញុំនឹងឲ្យថ្លៃឯងប្រាក់ស្ពាន់ពីរដុំ » " ។

" ខ្ញុំខំប្រឹងចម្លងខ្លាំងណាស់ ប៉ុន្តែអត្ថបទនោះវែងពេក នៅពេលគាត់មកដល់ ខ្ញុំចម្លងមិនទាន់ចប់នៅឡើយ។ អាលហ្គាមីស ខឹងខ្លាំងណាស់ ខឹងរហូតដល់ចង់វាយខ្ញុំឲ្យស្លាប់បើជាអ្នកបម្រើរបស់គាត់។ ប៉ុន្តែខ្ញុំមិនខ្លាចទេ ព្រោះគាត់គ្មានសិទ្ធវាយខ្ញុំឡើយ ពេលនោះខ្ញុំក៏និយាយទៅគាត់ថា ៖ អាលហ្គាមីស លោកជាអ្នកមានម្នាក់។ បើលោកប្រាប់ខ្ញុំពីអាថ៌កំបាំងដើម្បីក្លាយជាអ្នកមាន យប់នេះខ្ញុំនឹងខំប្រឹងចម្លង ហើយនៅពេលថ្ងៃរះអត្ថបទនេះនឹងចម្លងចប់ " ។

គាត់ក៏ញញឹមនិងតបថា៖ “ ឯងជាអ្នកបម្រើ តែមានសេចក្តីក្លាហាន ឥលូវយើងសម្រេចអញ្ចឹងចុះ ”

“ ខ្ញុំខំប្រឹងចម្លងអត្ថបទនោះដាក់លើបន្ទះដីឥដ្ឋអស់ពេញមួយយប់ រហូតដល់ឈឺចុកពេញខ្នង ឯក្លិនផ្សែងចង្កៀងធ្វើឲ្យខ្ញុំឈឺក្បាលទ្បើងស្រវាំងភ្នែក។ ប៉ុន្តែពេលគាត់មកដល់នៅពេលថ្ងៃរះ អត្ថបទនោះក៏ត្រូវបានចម្លងចប់ ” ។

“ ឥលូវប្រាប់ខ្ញុំមក តាមការសន្យា ” ខ្ញុំនិយាយ

“ ឯងពិតជាអាចចម្លងបានចប់មែន ” គាត់សរសើរ “ ហើយខ្ញុំក៏ត្រូវធ្វើតាមការសន្យាដែរ ។ ខ្ញុំនឹងប្រាប់អាថ៌កំបាំងទៅឯង ដោយសារឥលូវខ្ញុំចាស់ណាស់ទៅហើយ ដូច្នេះត្រូវតែនិយាយទាន់អណ្តាតនៅអាចក្រលាស់បាន។ **នៅពេលឈានដល់យុវវ័យ មនុស្សត្រូវតែស្វែងរកចំណេះដឹង** ” ។

“ គំនិតរបស់យុវវ័យ ” គាត់បានបន្ត “ ដូចដុំភ្លើងដែលកំពុងឆេះនៅលើអាកាសអញ្ចឹង គឺឆេះហើយក៏រលត់ទៅវិញ ចំណែកឯ **ចំណេះដឹង** វិញ គឺមិនផ្លាស់ប្តូរនោះទេ។ ចំណេះដឹង គឺដូចជាផ្កាយនៅលើមេឃ ដែលមិនផ្លាស់ប្តូរទីតាំង រហូតដល់នាវាចរអាចធ្វើដំណើរលើមហាសាគរដោយយកវាធ្វើជាគោលចរបានថែមទៀតផង ” ។

“ ស្តាប់ឲ្យច្បាស់ បើមិនយល់ខ្លឹមសារខ្ញុំចង់និយាយប្រាប់ទេ ឯងប្រាកដជាគិតថាវាគឺមិនសំខាន់ ហើយគិតថាការប្រឹងប្រែងរបស់ឯងមួយយប់នេះគឺខាតប្រយោជន៍ទទេ ” ។

ពេលនោះគាត់សម្លឹងចំមុខខ្ញុំ និងនិយាយដោយសម្លេងធ្ងន់ៗ តិចៗថា “ អាថ៌កំបាំងធ្វើឲ្យខ្ញុំក្លាយជាអ្នកមានគឺ **ដកប្រាក់មួយផ្នែកពីប្រាក់ចំណូលដែលរកបានដើម្បីសន្សំទុក** ហើយប្រាក់សន្សំនោះនឹងក្លាយជាប្រាក់របស់ឯង។ បើធ្វើបែបហ្នឹងកើត ឯងនឹងក្លាយជាអ្នកមានម្នាក់ ” ។

ដោយគាត់នៅបន្តសម្លឹងមិនដាក់ភ្នែក ខ្ញុំរង់ចាំស្តាប់បន្តទៀត តែគាត់អត់និយាយអ្វីទៀតទេ

“ តែប៉ុណ្ណឹងឯង ? ” ខ្ញុំសួរដោយឆ្ងល់

“ប៉ុណ្ណឹងក៏អាចធ្វើឲ្យអ្នកកង្វាលចៀមម្នាក់ក្លាយជាអ្នកមានលុយចងការឲ្យគេបានដែរ ” គាត់ឆ្លើយតប

“ ប៉ុន្តែប្រាក់ទាំងអស់ដែលខ្ញុំរកបានគឺសុទ្ធតែជារបស់ខ្ញុំ ឬមួយក៏មិនមែនទេ ? ” ខ្ញុំជជីកសួរ

“មិនមែនទេ” គាត់ឆ្លើយ “ ចុះឯងមិនឲ្យប្រាក់ហ្នឹងទៅជាងដេរសម្លៀកបំពាក់ទេអី? ឯងមិនឲ្យប្រាក់ទៅអ្នកលក់ស្បែកជើងទេអី ? ចុះឯងចំណាយលើម្ហូបអាហារដែរអត់ ? ឯងអាចរស់នៅបាប៊ីឡូនដោយមិនចំណាយប្រាក់មួយសេនបានដែរទេ ? គឺមាត់របស់ឯងស៊ីប្រាក់ដែលរកបាន។ ល្ងង់មែន! ឯងកំពុងរកលុយឲ្យគេ មិនមែនឲ្យខ្លួនឯងនោះទេ គឺកំពុងធ្វើការឲ្យគេ ។ ដូចទាសករអញ្ចឹងខំធ្វើការឲ្យចៅហ្វាយដើម្បីបានរបស់ស៊ីនិងស្លៀកពាក់។ ប្រសិនបើឯងដកទុក ១០% ពីប្រាក់រកបាន តើក្នុងពេលដប់ឆ្នាំឯងសល់ប្រាក់ប៉ុន្មាន ? ”

ដោយសារខ្ញុំពូកែគិតលេខ ខ្ញុំក៏ឆ្លើយភ្លាមថា “ ខ្ញុំប្រហែលជាអាចសល់ប្រាក់ស្មើនឹងចំណូលរកបានក្នុងពេលមួយឆ្នាំ ” ។

“ និយាយត្រូវ តែត្រូវតែពាក់កណ្តាលទេ ” គាត់និយាយ “ ដុំមាសនីមួយៗដែលសន្សំទុកនឹងក្លាយជាទាសកររបស់ឯងហើយ។ ប្រាក់ស្ពាន់មួយដុំអាចជួយរកប្រាក់ស្ពាន់មួយដុំទៀត មានន័យថាវាអាចបង្កើតកូនឲ្យឯង។ បើក្លាយជាអ្នកមាន ពេលនោះប្រាក់ទាំងអស់ដែលឯងមាន នឹងធ្វើការជួយរកប្រាក់ឲ្យឯងបន្ថែមទៀត ហើយកូនរបស់វានឹងបង្កើតកូនជាបន្តបន្ទាប់ទៀត ពេលនោះទ្រព្យសម្បត្តិនឹងចេះតែច្រើនទៅៗ ” ។

“ ឯងគិតថាខ្ញុំកំពុងនិយាយកុហកមែនទេ” គាត់និយាយបន្ត “ នេះខ្ញុំកំពុងបង់ថ្លៃចម្លងអត្ថបទលើសរាប់ពាន់ដង បើឯងយល់អ្វីដែលខ្ញុំកំពុងពន្យល់គឺៈ « ដកប្រាក់មួយផ្នែកពីចំណូលដែលរកបានដើម្បីសន្សំទុក ហើយប្រាក់នោះនឹងក្លាយជាប្រាក់របស់ឯង »។ មិនត្រូវដកទុកឲ្យតិចជាង ១០% ឡើយ ទោះបីរក

ប្រាក់ចំណូលបានតិចយ៉ាងណាក៏ដោយ ហើយប្រាក់ ១០% ប៉ុណ្ណឹង ឯងប្រាកដជាអាចដកទុកបាន។ ចំណាយលើរបស់ប្រើប្រាស់ប្រចាំថ្ងៃជាមុនសិន។ មិនត្រូវទិញសម្លៀកបំពាក់និងស្បែកជើងច្រើនពេករហូតដល់អស់ប្រាក់សម្រាប់ទិញរបស់ផ្សេងៗទៀតឡើយ។ ត្រូវចាយយ៉ាងម៉េចឲ្យសល់ប្រាក់គ្រប់គ្រាន់សម្រាប់ទិញម្ហូបអាហារ ប្រាក់សម្រាប់ចូលរួមសកម្មភាពមនុស្សធម៌ និងប្រាក់សម្រាប់ធ្វើបុណ្យធ្វើទាន ”។

“ **ទ្រព្យសម្បត្តិដូចជាដើមឈើអញ្ចឹង គឺដុះចេញពីគ្រាប់ពូជតូចមួយ**។ ប្រាក់ស្ពាន់មួយដុំដែលឯងសន្សំទុក គឺជាគ្រាប់ពូជមួយដែលនឹងដុះទៅជាឈើមាស ឈើប្រាក់។ បើប្រញាប់ប្រញាល់ចាប់ផ្តើមដាំគ្រាប់ពូជនេះ ឯងនឹងឆាប់បានផល ហើយក៏ត្រូវចេះថែទាំ ស្រោចទឹកជាប្រចាំ មានន័យថា ត្រូវតែខំសន្សំឲ្យជាប់ កុំឲ្យដាច់ឲ្យសោះ មិនយូរទេឯងនឹងបានអង្គុយក្រោមម្លប់ឈើមាស ឈើប្រាក់មិនខាន ”។

និយាយចប់ គាត់ក៏ទាញយកអត្ថបទចម្លង ហើយដើរចេញទៅ

“ ខ្ញុំយកពាក្យសម្តីគាត់មកគិត និងមើលទៅដូចសមហេតុសមផលដែរ ដូច្នេះខ្ញុំក៏សម្រេចចិត្តសាកល្បង។ ពេលខ្ញុំទទួលបានប្រាក់ចំណូលម្តងៗ ខ្ញុំដកទុកប្រាក់ស្ពាន់មួយដុំ។ រឿងចម្លែកបំផុតនោះគឺនៅត្រង់ថា ទោះបីខ្ញុំបានដកប្រាក់ខ្លះទុក ខ្ញុំនៅតែអាចចាយគ្រប់គ្រាន់ដូចពីមុនដដែល គ្មានខ្វះខាតអ្វីទេ។ ខ្ញុំចេះតែបន្តធ្វើម្តងហើយម្តងទៀតរហូតដល់ក្លាយជាទម្លាប់ ហើយពេលណាខ្ញុំមិនដកទុកទេ ខ្ញុំមានអារម្មណ៍មិនស្ងប់ចិត្តឡើយ។ នៅពេលខ្ញុំមានប្រាក់កាន់តែច្រើន ខ្ញុំចេះតែមានចិត្តចង់ទិញរបស់ល្អៗ ដែលអ្នកជំនួញនាំចូលមកពី ហ្វីនេហ្សា (Phoenicia)។ ប៉ុន្តែខ្ញុំឆ្លាតអាចហាមឃាត់ចិត្តខ្លួនឯងបាន ”។

ដប់ពីរខែក្រោយមក អាលហ្គាមីស បានត្រលប់មកនិយាយជាមួយខ្ញុំម្តងទៀត “ យ៉ាងម៉េចហើយ មួយឆ្នាំមកនេះ ឯងចាយវាយគ្រប់គ្រាន់អត់បន្ទាប់ពីដកប្រាក់ ១០% ទុក ? ”

ខ្ញុំឆ្លើយដោយមោទនៈភាព “ បាទ លោកគ្រូ ” ។

គាត់ញញឹម “ ល្អហើយអញ្ចឹង ចុះឯងយកប្រាក់សន្សំទៅធ្វើអី ? ”

“ ខ្ញុំឲ្យវាទៅ អាហ្សមើ(Azmur) ជាជាងធ្វើឥដ្ឋ ។ គាត់ប្រាប់ខ្ញុំថា គាត់នឹងធ្វើដំណើរតាមសមុទ្រទៅទីក្រុង ថាយ្យ(Tyre) ហើយគាត់នឹងទិញគ្រឿងអលង្ការ ប្លែកៗរបស់ជនជាតិ ហ្វេនីស៊ី (Phoenician) ឲ្យខ្ញុំ ។ ពេលគាត់មកវិញ យើងនឹងលក់វាក្នុងតម្លៃខ្ពស់ បន្ទាប់មកយើងចែកប្រាក់គ្នា ” ។

“ ហ៊ឹម ... មនុស្សល្ងង់ ត្រូវតែបង្រៀនឲ្យបានច្រើន! ” គាត់និយាយគ្រវីក្បាល “ ឯងយល់ថា ជាងធ្វើឥដ្ឋមានចំណេះដឹងខាងគ្រឿងអលង្ការដែលទេ ? បើឯងចង់ដឹងអំពីតារាសាស្ត្រ ហើយទៅសួរជាងធ្វើឥដ្ឋ តើគាត់ដឹងដែលអត់ ? អត់ទេ .. ទៅសួរតារាវិទូបានត្រូវ ។ ឥលូវប្រាក់សន្សំទាំងប៉ុន្មានត្រូវបាត់បង់អស់ហើយ ព្រោះឯងបានដកដើមឈើប្រាក់មកទាំងឫស ប៉ុន្តែអាចចាប់ផ្តើមដាំម្តងទៀត។ ព្យាយាមម្តងទៀត ហើយថ្ងៃក្រោយ បើឯងចង់ដឹងអំពីគ្រឿងអលង្ការ ត្រូវទៅសួរឈ្មួញខាងគ្រឿងអលង្ការ។ បើចង់ដឹងអំពីសត្វចៀម ត្រូវទៅសួរអ្នកកង្វាលចៀម។ **ចំណេះដឹងគឺនៅគ្រប់ទីកន្លែង មិនខ្វះទេ ហើយគ្មាននរណាកំណាញ់មិនចង់ប្រាប់ឯងនោះឡើយ ប៉ុន្តែត្រូវជ្រើសរើសយកចំណេះដឹងមួយណាចាំបាច់**។ អ្នកចង់ដឹងពីរបៀបសន្សំប្រាក់ តែបែរជាទៅសួរមនុស្សដែលគ្មានជំនាញខាងលុយកាក់ ប្រាកដជាបរាជ័យ ” និយាយរួចគាត់ក៏ដើរចេញទៅ។

ដូចគាត់បាននិយាយមែន។ ជនជាតិ ហ្វេនីស៊ី ដែលមានគំនិតបោកប្រាស់ បានលក់ទៅឲ្យ អាហ្សមើ នូវដុំកែវថ្លា ដែលមើលទៅដូចជាដុំត្បូង។ ប៉ុន្តែដូចការណែនាំរបស់ អាសហ្គាមីស អញ្ចឹង ខ្ញុំចាប់ផ្តើមសន្សំម្តងទៀត ព្រោះរឿងសន្សំប្រាក់បានក្លាយជាទម្លាប់ទៅហើយ ដូច្នេះវាមិនពិបាកទៀតទេសម្រាប់ខ្ញុំ ។

ដប់ពីរខែក្រោយមក អាហ្គាមីស ដើរចូលមកក្នុងបន្ទប់អ្នកចម្លងអក្សរ និងជួបខ្ញុំម្តងទៀត ។ “ តាំងពីយើងបែកគ្នា ឯងរីកចម្រើនបានប៉ុន្មានហើយ ? ”

“ ខ្ញុំចាយគ្រប់គ្រាន់លើការចំណាយប្រចាំថ្ងៃ ” ខ្ញុំឆ្លើយតប “ ហើយខ្ញុំ

បានឲ្យប្រាក់សន្សំរបស់ខ្ញុំទៅ អេកហ្គើ(Agger) ដែលជាជាងធ្វើខែល។ គាត់យកប្រាក់នោះទៅទិញទង់ដែង ហើយឲ្យប្រាក់ការមកខ្ញុំក្នុងពេលបួនខែម្តង ”។

“ ល្អ ! ចុះធ្វើអីទៀតជាមួយប្រាក់ការដែលឯងទទួលបាន ? ”

“ ខ្ញុំយកវាទៅទិញ ទឹកឃ្មុំ ស្រា និងនំប្រៃ ព្រោះខ្ញុំចូលចិត្តវា។ ខ្ញុំក៏បានទិញអាវផាយមួយដែលមានពណ៌ល្អស្អាត។ ហើយថ្ងៃក្រោយ ខ្ញុំនឹងទិញសត្វលាមួយទុកគ្រាន់ជិះ ” ។ អាលហ្គាមីស សើច “ ឥលូវឯងកំពុងស៊ីកូនរបស់ប្រាក់សន្សំហើយ។ ធ្វើអញ្ចឹង តើសង្ឃឹមថាឲ្យវាធ្វើការឲ្យឯងម៉េចកើត បើវាគ្មានកូន វាក៏គ្មានចៅដែរ។ ទីមួយត្រូវធ្វើវាឲ្យទៅជាទាសកររបស់ឯងជាមុនសិន ពេលវាបង្កើតកូនចៅបានច្រើនហើយ ឯងអាចចាយវាយដោយគ្មានភ័យព្រួយ ” ។ និយាយរួចគាត់ក៏ដើរចេញទៅ ។

បន្ទាប់ពីខានជួបរយៈពេលពីរឆ្នាំ អាលហ្គាមីស បានត្រលប់មកម្តងទៀត។ ពេលនោះមុខគាត់ឡើងជ្រៀវជ្រួញ ហើយភ្នែកសំយុងធ្លាក់ចុះក្រោម ព្រោះគាត់កាន់តែចាស់ណាស់ទៅហើយ។ គាត់និយាយមកកាន់ខ្ញុំ “ អាខេដ តើឯងទទួលបានទ្រព្យសម្បត្តិដែលឯងប្រាថ្នាចង់បានហើយនៅ ? ”

ខ្ញុំឆ្លើយ “ មិនទាន់ទេ ប៉ុន្តែខ្ញុំបានប្រើប្រាក់ឲ្យធ្វើការឲ្យខ្ញុំ ហើយវាបង្កើតប្រាក់ជាបន្តបន្ទាប់ ”

“ ចុះឯងសួរយោបល់ពីជាងធ្វើឥដ្ឋទៀតទេ ? ”

“ បើចង់សួរពីរឿងធ្វើឥដ្ឋ ខ្ញុំនឹងទៅសួរគាត់ ” ខ្ញុំនិយាយបែបកំប្លែង

“ អាខេដ ” គាត់និយាយបន្ត “ ឯងរៀនមេរៀននេះបានល្អណាស់។ មុនដំបូង ឯងរៀនដកប្រាក់ខ្លះពីប្រាក់ចំណូលដើម្បីសន្សំទុក។ បន្ទាប់មក ឯងរៀនស្វែងរកយោបល់ពីមនុស្សណាដែលមានចំណេះ និងបទពិសោធន៍។ ហើយចុងក្រោយ ឯងបានរៀនប្រើប្រាក់ដើម្បីធ្វើការឲ្យឯង ” ។

“ ឯងបង្ហាត់ខ្លួនឯង ពីរបៀបរកលុយ ពីរបៀបសន្សំលុយ និង ពីរបៀបប្រើលុយដើម្បីបង្កើតលុយ។ ដូច្នេះឥលូវឯងមានជំនាញគ្រប់គ្រាន់លើបញ្ហាលុយ

កាក់ហើយ។ ខ្ញុំចាស់ណាស់ហើយ ឯកូនខ្ញុំវិញគិតតែពីស៊ីចាយ គ្មានគំនិតខាងរកប្រាក់សោះ។ ទ្រព្យសម្បត្តិរបស់ខ្ញុំមានច្រើន ខ្លាចក្រែងតែមិនអាចមើលថែវាបាន។ ប្រសិនបើឯងយល់ព្រមទៅទីក្រុង នីពភើ (Nippur) ដើម្បីមើលថែទ្រព្យសម្បត្តិរបស់ខ្ញុំនៅទីនោះ ខ្ញុំនឹងយកឯងធ្វើជាដៃគូ ហើយឯងនឹងទទួលមរតករបស់ខ្ញុំមួយចំណែក " ។

" ខ្ញុំក៏សម្រេចចិត្តទៅទីក្រុង នីពភើ ដើម្បីមើលការខុសត្រូវទ្រព្យសម្បត្តិរបស់ អាលហ្គាមីស ជាច្រើននៅទីនោះ។ ដោយសារតែជាមនុស្សមានមហិច្ឆតាខ្ពស់ព្រមទាំងស្ទាត់ជំនាញខាងក្បួនច្បាប់ទាំងបីប្រការដើម្បីចាត់ចែងទ្រព្យសម្បត្តិឲ្យបានជោគជ័យផង ខ្ញុំបានធ្វើឲ្យទ្រព្យសម្បត្តិគាត់កាន់តែកើនឡើងថែមទៀត។ បន្ទាប់ពីគាត់ទទួលមរណៈភាពទៅ ខ្ញុំទទួលបានទ្រព្យសម្បត្តិមួយចំនួនទៅតាមផ្លូវច្បាប់ត្រឹមត្រូវ " ។

នេះគឺជាប្រវត្តិរបស់ អាខេដ។ នៅពេលគាត់និយាយចប់ មានមិត្តភក្តិម្នាក់និយាយ " លោកពិតជាសំណាងមែនដែល អាលហ្គាមីស ទទួលលោកជាអ្នកទទួលមរតក " ។

" តាមពិត សំណាងហ្នឹងគឺកើតចេញពីការតាំងចិត្តចង់ក្លាយជាអ្នកមានម្នាក់ នៅមុនពេលខ្ញុំបានជួបគាត់ទៅទៀត។ អស់រយៈពេលបួនឆ្នាំដែលខ្ញុំតាំងចិត្តដកប្រាក់ ១០% ពីប្រាក់ចំណូល មកសន្សំទុក។ តើលោកអាចហៅអ្នកនេសាទម្នាក់ថាជាមនុស្សជោគជ័យបានទេ បើគាត់ចេះតែអង្គុយសិក្សាអំពីត្រីរាប់ឆ្នាំ ប៉ុន្តែមិនដែលបង់សំណាញ់ដើម្បីចាប់ត្រីសោះ? **ឱកាស** ឆ្មើងខ្លាំងណាស់ មិនចំណាយពេលរង់ចាំនរណាម្នាក់ដែលមិនព្រមចាប់វានោះទេ " ។

" លោកមានកម្លាំងចិត្តខ្លាំងដែលអាចចាប់ផ្តើមសន្សំម្តងទៀតបន្ទាប់ពីបាត់ប្រាក់អស់នៅលើកទីមួយ។ លោកពិតជាមនុស្សមិនធម្មតាមែន! " ម្នាក់ទៀតនិយាយ

" កម្លាំងចិត្ត? " អាខេដ និយាយបែបចំអន់ " មិនមែនកម្លាំងចិត្តទេ។

លោកគិតថាកម្លាំងចិត្តអាចធ្វើឲ្យមនុស្សម្នាក់លើកបារទំនិញដែលសត្វអូដ្ឋដឹក មិនរួចមែនទេ ឬក៏ អូសទម្ងន់ដែលសត្វគោមិនអាចទាញរួចមែនទេ? **តាមពិត កម្លាំងចិត្តគឺកើតចេញពី ការតាំងចិត្តដ៏មុះមុត ដើម្បីធ្វើកិច្ចការណាមួយដែលខ្លួនបានកំណត់ថាត្រូវធ្វើ ឲ្យបានសម្រេច**។ បើខ្ញុំតាំងចិត្តធ្វើកិច្ចការមួយហើយ ទោះបីវាជាការងារកំប៉ិចកំប៉ុកក៏ដោយ ក៏ខ្ញុំត្រូវតែធ្វើរហូតដល់បានសម្រេច ពេលនោះកម្លាំងចិត្តនឹងកើតឡើង ហើយកម្លាំងចិត្តនោះនឹងជួយជំរុញខ្ញុំឲ្យធ្វើកិច្ចការសំខាន់ៗផ្សេងទៀត។ ឧទាហរណ៍ បើខ្ញុំសន្យានឹងខ្លួនឯងថា « ក្នុងរយៈពេល ១០០ថ្ងៃ ពេលណាខ្ញុំដើរកាត់ស្ពានទៅផ្សារ ខ្ញុំនឹងរើសថ្មមួយដុំហើយគប់វាចូលទៅក្នុងទន្លេ » ខ្ញុំនឹងធ្វើវា។ បើនៅថ្ងៃទីប្រាំពីរ ខ្ញុំដើរកាត់ស្ពានតែភ្លេចរើសដុំថ្មដើម្បីគប់ទៅក្នុងទន្លេ ខ្ញុំនឹងមិននិយាយដោះសារថា « ចាំថ្ងៃស្អែកខ្ញុំនឹងគប់ថ្មពីរដុំតែម្តង » នោះទេ ។ ផ្ទុយមកវិញ ខ្ញុំនឹងចាប់ផ្តើមធ្វើវាសារឡើងវិញ។ ហើយខ្ញុំក៏មិននិយាយថា « អាខេដ ធ្វើអញ្ចឹងគ្មានប្រយោជន៍ទេ! តើបានប្រយោជន៍អីដែលត្រូវគប់ដុំថ្មម្តងមួយៗទៅក្នុងទន្លេរាល់ថ្ងៃ? ម៉េចក៏មិនកើបពេញមួយដៃហើយគប់សរុបតែម្តងទៅ? » ។ **បើខ្ញុំសម្រេចចិត្តធ្វើអ្វីមួយហើយ ខ្ញុំនឹងធ្វើវារហូតដល់ចប់**។ ដូច្នេះហើយទើបខ្ញុំប្រយ័ត្នប្រយែងណាស់ ខ្ញុំមិនចង់សម្រេចចិត្តធ្វើកិច្ចការណាដែលមើលទៅមិនអាចទៅរួចនោះទេ ” ។

បន្ទាប់មកម្នាក់ទៀតចាប់ផ្តើមនិយាយ “ ស្តាប់មើលទៅដូចជាសាមញ្ញណាស់ ហើយបើត្រឹមត្រូវដូចលោកនិយាយមែន យើងគ្រប់ៗគ្នាប្រាកដជាអាចក្លាយជាអ្នកមានម្នាក់បាន ប៉ុន្តែបើមនុស្សទាំងអស់ក្លាយជាអ្នកមាន តើមានប្រាក់គ្រប់គ្រាន់សម្រាប់គ្រប់ៗគ្នាដែលអត់ ? ”

“ ទ្រព្យសម្បត្តិអាចដុះបាន ហើយដុះត្រង់កន្លែងណាដែលមានមនុស្សខំប្រឹងប្រែងធ្វើការ ” អាខេដ ឆ្លើយតប “ បើអ្នកមានម្នាក់សង់វីឡាមួយដ៏ធំស្កឹមស្កៃ តើមាសដែលគាត់ចំណាយត្រូវបាត់បង់អស់មែនទេ? អត់ទេ! ជាងធ្វើឥដ្ឋបានមួយចំណែក កម្មករទទួលបានមួយចំណែក ឯជាងគំនូរក៏បានមួយ

ចំណែកដែរ។ ហើយមនុស្សគ្រប់ៗគ្នាដែលចូលរួមក្នុងសំណង់នោះទទួលបានមួយចំណែករៀងៗខ្លួន ប៉ុន្តែនៅពេលវីឡានោះត្រូវបញ្ចប់ តើវាមានប្រយោជន៍សមនឹងតម្លៃដែលចំណាយទាំងអស់នោះទេ? វាប្រាកដជានាំប្រយោជន៍។ ដីដែលនៅជុំវិញវីឡានេះនឹងឡើងថ្លៃដោយសារអាគារមួយនេះ។ ទ្រព្យសម្បត្តិដុះឡើងដោយចម្លែក ហើយគ្មាននរណាម្នាក់អាចទាយពីទំហំរបស់វាបានទេ។ មើលជនជាតិ ហ្វេនីស៊ី ដែលបានកសាងទីក្រុងធំៗជាច្រើននៅតាមតំបន់ឆ្នេរសមុទ្រ តែដីនៅតំបន់នោះគ្មានជីជាតិសោះ តើពួកគេបានទ្រព្យមកពីណាដើម្បីកសាងទីក្រុងទាំងអស់នោះ? គឺបានមកពីពាណិជ្ជកម្មដែលពួកគេធ្វើតាមផ្លូវសមុទ្រនោះឯង "

" បើអញ្ចឹង តាមយោបល់លោក តើយើងគួរធ្វើយ៉ាងណាដើម្បីក្លាយជាអ្នកមានបាន? " បុរសម្នាក់ទៀតបានសួរ " ពេលវេលាចេះតែកន្លងផុតទៅ យើងកាន់តែចាស់ឡើងៗ ហើយយើងគ្មានអ្វីសល់សោះ " ។

អាខេដ ឆ្លើយ ៖ " អ្នកទាំងអស់គ្នាគួរតែរៀនក្បួនរបស់ អាលហ្កាមីសទៅ គឺត្រូវទន្ទេញវារាល់ថ្ងៃ ៖ «ខ្ញុំត្រូវដកប្រាក់ចំណូលមួយផ្នែកដើម្បីសន្សំទុក» ។ ត្រូវទន្ទេញវាឲ្យបានបីដងក្នុងថ្ងៃ នៅពេលភ្ញាក់ពីដំណេក នៅពេលថ្ងៃ និងនៅពេលយប់។ ក្រោយមក ត្រូវទន្ទេញវារាល់ម៉ោងនិងរាល់ថ្ងៃ។ ទន្ទេញរហូតដល់អស់លោកអាចឃើញពាក្យលេចឡើងនៅលើមេឃ " ។

" ត្រូវធ្វើខ្លួនឯងឲ្យចូលចិត្តក្បួនមួយហ្នឹង។ ត្រូវធ្វើឲ្យខួរក្បាលពេញទៅដោយក្បួនមួយហ្នឹង។ បន្ទាប់មកត្រូវអនុវត្ត ដោយដកសន្សំទុកចំនួនប្រាក់ប៉ុន្មានក៏ដោយឲ្យតែគិតថាសមល្មម ប៉ុន្តែមិនត្រូវឲ្យតិចជាង ១០% ឡើយ។ បើយល់ល្អគួររៀបចំផែនការណ៍ចំណាយប្រចាំថ្ងៃ ប៉ុន្តែការដកប្រាក់ដើម្បីសន្សំទុកត្រូវធ្វើមុនគេ។ មិនយូរទេអ្នកទាំងអស់គ្នានឹងកើតចិត្តស្រលាញ់ប្រាក់ នៅពេលឃើញប្រាក់សល់នៅក្នុងកាបូប និងនៅពេលចំនួនប្រាក់ចេះតែកើនឡើង វានឹងធ្វើឲ្យអ្នកទាំងអស់គ្នាមានកម្លាំងចិត្តកាន់តែខ្លាំង គឺមានទឹកចិត្តប្រឹងប្រែងធ្វើការ ហើយការប្រឹងប្រែងនេះនឹងបង្កើនប្រាក់ចំណូលឲ្យអ្នកកាន់តែច្រើន។ នៅពេលប្រាក់ចំណូល